**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**

**គណៈកម្មាធិការលទ្ធកម្ម**

លេខ : 1188 PEAC.អក

## សេចក្តីជូនដំណឹង

**ស្តីពីការងារតំលើង VIDEO CONFERENCE នៅ NCC និងសាលប្រជុំ**

**នាយកដ្ឋានផែនការយុទ្ធសាស្ត្រនិងគម្រោងការ**

**ជូននាយកដ្ឋានបញ្ជូនអគ្គិសនី**

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា : អគ្គិសនីកម្ពុជានឹងដាក់ឱ្យពិគ្រោះថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការងារ ស្តីពីការងារតំលើង VIDEO CONFERENCE នៅ NCC និងនៅសាលប្រជុំនាយកដ្ឋានផែនការយុទ្ធសាស្ត្រនិងគម្រោងការ ជូននាយកដ្ឋានបញ្ជូនអគ្គិសនី ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ក្រុមហ៊ុន / សហគ្រាសបំពេញដើម្បីចូលរួមពិគ្រោះថ្លៃ ។ ឯកសារពិគ្រោះថ្លៃមានដាក់លក់នៅអង្គភាពលទ្ធកម្មដែលមានអាស័យដ្ឋាន :ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញចាប់ពី ថ្ងៃទី ១៥-០៨-២០១៦ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ : 023 67 66 007 និង Website www.edc.com.kh) ។

ឯកសារពិគ្រោះថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹម ថ្ងៃទី ៣០-០៨-២០១៦ វេលាម៉ោង ១១:00 នាទី ។

ការបើកសំណើពិគ្រោះថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាសយដ្ឋានខាងលើវេលាម៉ោង ១៥ : ០០នាទី ថ្ងៃទី ៣០-០៨-២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើពិគ្រោះថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/ សហគ្រាសដែលមានបំណងចូលរួមពិគ្រោះថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារពិគ្រោះថ្លៃ និង សាកសួរពតិមានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី 17 ខែ សីហា ឆ្នាំ ២០១៦

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ឝីង_អ៊ុង**

ចម្លងជូន :

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ